អង្គការពលកម្មអន្តរជាតិ

រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

# ដំណើរការនៃការត្រួតពិនិត្យ







- គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* គឺជាកម្មវិធីត្រួតពិនិត្យលើការអនុវត្តន៏តាមច្បាប់ និង កែលំអរោងចក្រ របស់អង្គការពលកម្មអន្តរជាតិ (ILO) ដែលជាទីភ្នាក់ងារឯកទេសរបស់អង្គការសហប្រជាជាតិ និងទទួលបានការគាំទ្រពី រាជរដ្ឋាភិបាលកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា សហជីព និង អ្នកបញ្ជាទិញអន្តរជាតិ ។

- ការចូលរួមរបស់រោងចក្រនៅក្នុងកម្មវិធីនេះ គឺឈរលើគោលការណ៏ស្ម័គ្រចិត្ត ប៉ុន្តែការចូលរួមនេះបានក្លាយជាល័ក្ខខ័ណ្ឌដើម្បីទទួលបាន អាជ្ញាប័ណ្ណនាំចេញ ដែលតំរូវដោយក្រសួងពាណិជ្ជកម្មនៃប្រទេសកម្ពុជា។

- កម្មវិធីនេះត្រួតពិនិត្យមើលល័ក្ខខ័ណ្ឌការងារនៅក្នុងវិស័យកាត់ដេរ ដោយផ្អែកលើច្បាប់ស្តីពីការងាររបស់ប្រទេសកម្ពុជា និង បទដ្ឋានការងារអន្តរជាតិ ។

- របាយការណ៏ត្រួតពិនិត្យសំរាប់រោងចក្រត្រូវបានរក្សាជាការសំងាត់ ប៉ុន្តែរោងចក្រអាចផ្តល់សិទ្ធិអោយភាគីទីបីដូចជាអ្នកបញ្ជាទិញជាដើម ចូលមើលរបាយការណ៏របស់ពួកគេបាន ។ របាយការណ៏ត្រួតពិនិត្យសំរាប់រោងចក្រ មានរៀបរាប់យ៉ាងលំអិតអំពីលទ្ធផលដែលបានរកឃើញ និងសំណូមពរសំរាប់ការកែលំអ ។

- រោងចក្រ អាចបដិសេធចំពោះលទ្ធផលដែលបានរកឃើញនៅក្នុងរបាយការណ៏របស់ពួកគេ និង/ឬ ចុះផ្សាយផែនការសកម្មភាពកែតំរូវដើម្បីបង្ហាញពីគោលបំណងរបស់ពួកគ ក្នុងការកែលំអល័ក្ខខ័ណ្ឌការងារនៅក្នុងរោងចក្រ ។

- ទិន្នន័យនៃការអនុវត្តន៏តាមច្បាប់ ត្រូវបានចេញផ្សាយជាសាធារណៈតាមរយៈវ៉ិបសាយរបស់គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៅក្នុងរបាយការណ៏សំយោគ និង របាយការណ៏ដែលបង្ហាញពីវឌ្ឍនភាពរបស់រោងចក្រនីមួយៗ ។

# ដំណាក់កាលសំខាន់ៗ

## ១. ការចុះឈ្មោះ

រោងចក្រចុះឈ្មោះជាមួយនឹងកម្មវិធី ហើយទទួលបានព័ត៌មានជាមូលដ្ឋានទាក់ទងនឹងដំណើរការនៃការត្រួតពិនិត្យ ។

## ២. ការចុះត្រួតពិនិត្យដោយមិនជូនដំណឹងជាមុន

ការចុះត្រួតពិនិត្យដោយមិនជូនដំណឹងជាមុនត្រូវបានធ្វើឡើង ក្នុងនោះមានកិច្ចប្រជុំជាមួយអ្នកគ្រប់គ្រង ប្រតិភូបុគ្គលិក អ្នកដឹកនាំសហជីព និង កម្មករនិយោជិត ។ ឯកសារត្រូវបានត្រួតពិនិត្យ ហើយកន្លែងធ្វើការត្រូវបានសង្កេតមើល ។

## ៣. ការរៀបចំរបាយការណ៍

ភ័ស្តុតាងជាឯកសារដែលរោងចក្រផ្តល់អោយត្រូវបានពិនិត្យ ហើយរបាយការណ៍ត្រូវបានរៀបចំ ។

## ៤. ការចេញផ្សាយរបាយការណ៍

បន្ទាប់ពីការពិនិត្យរួច របាយការណ៍ត្រូវចេញផ្សាយសំរាប់រោងចក្រ និង ភាគីទីបីដែលទទួលបានការអនុញ្ញាត ដូចជាអ្នកបញ្ជាទិញជាដើម ។

## ៥. ការបដិសេធ និង ផែនការសកម្មភាពកែតំរូវ

រោងចក្រអាចចុះផ្សាយការបដិសេធ និង ផែនការសកម្មភាពកែតំរូវ (CAPs) និង/ឬ ស្នើសុំអោយមានការបំភ្លឺលើបញ្ហានានាដែលជាក្តីកង្វល់ ។

## ៦. ការចុះត្រួតពិនិត្យតាមដានបន្ទាប់

ការចុះត្រួតពិនិត្យបន្ទាប់ រំពឹងថានឹងធ្វើឡើងក្នុងអំឡុងពេល ៦ ខែ ក្រោយ ដោយអាចត្រួតពិនិត្យលើបញ្ហាបន្ថែមជាក់លាក់ណាមួយ នៅគ្រប់ពេលវេលា ។

# ការចុះត្រួតពិនិត្យ

## ផ្នែកទី ១: ការប្រកាសពីការចុះត្រួតពិនិត្យ និង ការចូលទៅក្នុងរោងចក្រ

១. បុគ្គលិកត្រួតពិនិត្យរបស់អង្គការពលកម្មអន្តរជាតិធ្វើការណែនាំខ្លួននៅខ្លោងទ្វាររោងចក្រ និង/ឬ កន្លែងទទួលភ្ញៀវ និង ពន្យល់ពីគោលបំណងនៃការចុះមករបស់ពួកគេ ។

២. បន្ទាប់ពីទទួលបានការអនុញ្ញាតអោយចូលទៅក្នុងរោងចក្ររួចមក ពួកគេបន្តការងាររបស់ខ្លួនតាមដំណើរការនៃការចុះត្រួតពិនិត្យរបស់ពួកគេ (រយៈពេលរង់ចាំយូរបំផុតដែលអាចទទួលយកបានគឺ ៤៥ នាទី) ។

## ផ្នែកទី ២: ការពិនិត្យមើលផ្នែកខាងក្នុង និង ខាងក្រៅនៃបរិវេណរោងចក្រ

១. ការជួបប្រជុំ/សំភាសន៍ជាមួយនឹងអ្នកគ្រប់គ្រង
- ការណែនាំខ្លួន
- ការពន្យល់ពីដំណើរការនៃការត្រួតពិនិត្យ
- ការផ្តល់ព័ត៌មានទូទៅស្តីពីប្រព័ន្ធគ្រប់គ្រងព័ត៌មាន (IMS)
- ការផ្តល់ឯកសារទៅអោយអ្នកគ្រប់គ្រងដូចជា សំនួរដែលគេតែងសួរជាញឹកញាប់ (FAQs) ខិត្តប័ណ្ណពណ៌នាអំពីការត្រួតពិនិត្យ បែបបទផ្តល់សិទ្ធិប្រើប្រាស់ដល់ភាគីទីបី របាយការណ៍សំរាប់រោងចក្រដែលបានចេញផ្សាយលើកមុន សៀវភៅណែនាំអំពីច្បាប់ស្តីពីការងារ ព្រឹត្តិប័ត្រព័ត៌មាន ប័ណ្ណរឹបសាយ ។ល។
- ការសំភាសន៍ជាមួយនឹងអ្នកគ្រប់គ្រង ពាក់ព័ន្ធនឹងល័ក្ខខ័ណ្ឌការងារនៅក្នុងរោងចក្រ
- ការស្នើសុំបញ្ជីបើកប្រាក់ខែបច្ចុប្បន្ន និង ឯកសារដទៃទៀត

២. ការសំភាសន៍ជាមួយនឹងប្រតិភូបុគ្គលិក អ្នកដឹកនាំសហជីព និង កម្មករនិយោជិត

៣. ការសង្កេតលើទីកន្លែងធ្វើការ (ដូចជាការសំភាសន៍ជាមួយកម្មករនិយោជិត ការសង្កេតជាទូទៅ ការវាស់ស្ទង់សំលេង ភ្លើងបំភ្លឺ និង សីតុណ្ហភាព)

៤. កិច្ចប្រជុំបិទ
- បង្ហាញពីលទ្ធផលរកឃើញពាក់ព័ន្ធនឹងល័ក្ខខ័ណ្ឌការងារ (បញ្ជីត្រួតពិនិត្យសំរាប់កិច្ចប្រជុំបិទ)
- សំណើសុំឯកសារជាលាយលក្ខណ៍អក្សរ
- ការពន្យល់ពីសកម្មភាពក្រោយការត្រួតពិនិត្យ (សូមមើលខាងក្រោម)

### បញ្ហាសំខាន់ៗដែលត្រូវត្រួតពិនិត្យ (មិនមានគ្រប់ចំនុចទាំងអស់នោះទេ)

**ល័ក្ខខ័ណ្ឌការងារ**
- កិច្ចសន្យា
- ប្រាក់ឈ្នួល
- ម៉ោងធ្វើការ
- ការឈប់សំរាក
- សុខមាលភាព

**សុវត្ថិភាព និង សុខភាពការងារ (OSH)**
- គោលនយោបាយ OSH
- គ្រោះថ្នាក់ការងារ/ជំងឺវិជ្ជាជីវៈ
- សំណងសំរាប់គ្រោះថ្នាក់ការងារ/ជំងឺវិជ្ជាជីវៈ
- វិធានការការពារ
- ភ្លើងបំភ្លឺ
- សំលេង
- ខ្យល់ចេញចូល និង កំដៅ
- គិលានដ្ឋាន

**ទំនាក់ទំនងការងារ និង សិទ្ធិជាមូលដ្ឋាន**
- សេរីភាពរបស់និយោជិតក្នុងការបង្កើតសមាគម
- ការរើសអើងប្រឆាំងនឹងសហជីព
- ប្រតិភូបុគ្គលិក
- មន្ត្រីទំនាក់ទំនង
- វិវាទរួម
- កូដកម្ម/ឡក់អៅ
- វិវាទបុគ្គល
- ការរើសអើង
- ពលកម្មកុមារ

## ផ្នែកទី ៣: សកម្មភាពក្រោយការត្រួតពិនិត្យ (ការបដិសេធ ផែនការសកម្មភាពកែតម្រូវ និង ការប្រជុំបំភ្លឺ)

១. រោងចក្រគួរផ្តល់គ្រប់ឯកសារទាំងអស់ដែលបានស្នើសុំ ក្នុងរយៈពេល ៧ ថ្ងៃ ក្រោយការចុះត្រួតពិនិត្យ ។

២. បុគ្គលិកត្រួតពិនិត្យនឹងសរសេររបាយការណ៍ និង ពិនិត្យមើលព័ត៌មានបន្ថែមដែលចាំបាច់ ។

៣. បន្ទាប់ពីរបាយការណ៍រួចរាល់ជាស្ថាពរ រោងចក្រត្រូវបានជូនដំណឹងថារបាយការណ៍នេះត្រូវបានចុះផ្សាយនៅលើប្រព័ន្ធ IMS ហើយអាចបើកមើលបានដោយប្រើឈ្មោះអ្នកប្រើប្រាស់ និង អក្សរសំងាត់ ។ ភាគីទីបីដែលទទួលបានការអនុញ្ញាត អាចចូលមើលរបាយការណ៍រោងចក្រនេះ ៥ ថ្ងៃបន្ទាប់ពីរបាយការណ៍ត្រូវបានចុះផ្សាយនៅលើប្រព័ន្ធ IMS ។ (រយៈពេលនៃការពន្យាពេល ៥ ថ្ងៃនេះ អាចផ្លាស់ប្តូរទៅតាមការស្នើសុំ)

៤. រោងចក្រមានរយៈពេល ២១ ថ្ងៃ (ដោយមិនគិតថ្ងៃចុងសប្តាហ៍) ដើម្បីចុះផ្សាយការបដិសេធរបស់ខ្លួន ។ ពុំមានការកំណត់ពេលវេលា ចំពោះការចុះផ្សាយផែនការសកម្មភាពកែតម្រូវឡើយ ។

- រោងចក្រត្រូវពិនិត្យសិក្សាលើរបាយការណ៍ជាបន្ទាន់ ដើម្បីត្រៀមឆ្លើយនឹងសំនួរនានាដែលអ្នកបញ្ជាទិញដែលទទួលបានការអនុញ្ញាតអាចសាកសួរ ។ ពួកគេក៏អាចស្នើអោយមានជាការប្រជុំជាមួយនឹងអង្គការពលកម្មអន្តរជាតិផងដែរ ដើម្បីស្វែងរកការបំភ្លឺលើបញ្ហានានាដែលបានលើកឡើងនៅក្នុងរបាយការណ៍ និង/ឬ ស្នើសុំជំនួយពីក្រុមបណ្តុះបណ្តាលរបស់ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ដើម្បីជួយពួកគេបង្កើត និង អនុវត្តផែនការសកម្មភាពកែតម្រូវ ។
- របាយការណ៍ត្រួតពិនិត្យ ឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃល័ក្ខខ័ណ្ឌការងារនៅក្នុងរោងចក្រ ដែលត្រូវបានសង្កេតឃើញនៅក្នុងពេលចុះត្រួតពិនិត្យ ។
- របាយការណ៍ត្រួតពិនិត្យរបស់គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ជាធម្មតាមិនរាប់បញ្ចូលនូវការគ្រោងទុកក្នុងការអនុវត្តន៍ទៅតាមល័ក្ខខ័ណ្ឌនានា ឬ សកម្មភាពដែលបានធ្វើក្រោយការចុះត្រួតពិនិត្យឡើយ ។

៥. កិច្ចប្រជុំបំភ្លឺជាមួយនឹងបុគ្គលិករបស់អង្គការពលកម្មអន្តរជាតិ អាចត្រូវបានរៀបចំឡើងទៅតាមការស្នើសុំ ដើម្បីធ្វើការពិភាក្សាអំពីលទ្ធផលដែលបានរកឃើញនៅក្នុងរបាយការណ៍ និង/ឬ សុំជំនួយដើម្បីដោះស្រាយបញ្ហានៃការមិនអនុវត្តន៍ទៅតាមច្បាប់ ។

- ប្រសិនបើរបាយការណ៍នៃការត្រួតពិនិត្យមានព័ត៌មានដែលមិនពិត គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* អាចពិនិត្យមើលរបាយការណ៍ឡើងវិញទៅតាមការវិនិច្ឆ័យរបស់ខ្លួន ។ នៅក្នុងករណីនេះ របាយការណ៍នឹងត្រូវបានកែតម្រូវ ហើយរោងចក្រនិងអ្នកបញ្ជាទិញដែលទទួលបានការអនុញ្ញាតនឹងត្រូវបានជូនដំណឹងស្តីពីការផ្លាស់ប្តូរដែលបានធ្វើឡើង ។
- កិច្ចប្រជុំបំភ្លឺអាចមានការចូលរួមពីសមាជិកម្នាក់របស់ក្រុមបណ្តុះបណ្តាលនៃគំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ដែលអាចពង្រាងការវាយតំលៃដំបូងលើតំរូវការ និង សំណូមពរសំរាប់សកម្មភាពកែតម្រូវ ដែលរោងចក្រអាចប្រើប្រាស់សំរាប់កែតម្រូវផ្នែកមិនអនុវត្តន៍ទៅតាមច្បាប់ និង សំរាប់ទំនាក់ទំនងជាមួយនឹងអ្នកបញ្ជាទិញផងដែរ ។
- បញ្ហាដែលហួសពីសមត្ថកិច្ចរបស់បុគ្គលិកត្រួតពិនិត្យដូចជា ការជជែកវែកញែកគោលនយោបាយអំពីច្បាប់ស្តីពីការងារ ជាធម្មតាមិនត្រូវបានដោះស្រាយនៅក្នុងកិច្ចប្រជុំបិទ ឬ កិច្ចប្រជុំបំភ្លឺឡើយ ។

# សេចក្តីសង្ខេបអំពីបុគ្គលិកត្រួតពិនិត្យ

បុគ្គលិកត្រួតពិនិត្យរបស់គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* គឺជាបុគ្គលិករបស់អង្គការពលកម្មអន្តរជាតិ (ILO) និងទទួលបានការបណ្តុះបណ្តាលអោយបំពេញភារកិច្ចរបស់ខ្លួន អោយស្របទៅតាមបទដ្ឋានខ្ពស់បំផុតរបស់អង្គការសហប្រជាជាតិ ។ ការងាររបស់ពួកគេមានមូលដ្ឋានលើក្រមសីលធម៌ដ៏តឹងរ៉ឹង ប្រកបដោយសុចរិតភាព តម្លាភាព ភាពជាការទូត និងសំខាន់ជាងគេបំផុតគឺ ការគោរពចំពោះមនុស្សគ្រប់រូបដែលពួកគេជួបជាមួយខណៈពេលដែលពួកគេកំពុងបំពេញការងារក្នុងនាមជាបុគ្គលិកត្រួតពិនិត្យរបស់អង្គការពលកម្មអន្តរជាតិ ។

បុគ្គលិកត្រួតពិនិត្យរបស់គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* មិនមែនជាអធិការការងារនោះឡើយ ហើយពួកគេមិនមានសមត្ថកិច្ចពង្រឹងការអនុវត្តន៍ច្បាប់ការងារឡើយ ។ ភារកិច្ចចំបងរបស់ពួកគេគឺ ចងក្រងឯកសារស្តីពីល័ក្ខខ័ណ្ឌការងារនៅក្នុងពេលចុះត្រួតពិនិត្យ តាមរយៈការសង្កេត ការសំភាសន៍ និង ការសិក្សាលើភ័ស្តុតាងជាឯកសារ ។ បុគ្គលិកត្រួតពិនិត្យរបស់*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* មានបទពិសោធន៍ និង មានចំណេះដឹងច្រើនអំពីច្បាប់ស្តីពីការងាររបស់ប្រទេសកម្ពុជា និង បទដ្ឋានការងារអន្តរជាតិ ហើយពួកគេអាចផ្តល់ការពិគ្រោះយោបល់ សំរាប់ការបញ្ជាក់បំភ្លឺនានាដែលពាក់ព័ន្ធនឹងការងាររបស់ពួកគេ ។

សំរាប់បញ្ហាណាដែលពាក់ព័ន្ធនឹងការបកស្រាយច្បាប់ស្តីពីការងារ ឬ ជំហររបស់អង្គការពលកម្មអន្តរជាតិចំពោះបញ្ហាការងារ រោងចក្រគប្បីទាក់ទងជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋាភិបាល ឬ ទាក់ទងមកកាន់ការិយាល័យគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ។

គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ប្រាថ្នាធ្វើការត្រួតពិនិត្យលើកន្លែងធ្វើការ ដោយមានការសហការយ៉ាងពេញលេញជាមួយនឹងគ្រប់ភាគីទាំងអស់ ហើយសូមសំដែងការកោតសរសើរយ៉ាងខ្ពង់ខ្ពស់ចំពោះការជួយសំរួលការងារទាំងអស់ដែលបានផ្តល់ទៅអោយបុគ្គលិកត្រួតពិនិត្យ នៅក្នុងពេលបំពេញភារកិច្ចរបស់ពួកគេ ។

នៅពេលដែលមានសំពាធ ឬ ការរំខានដល់ដំណើការនៃការត្រួតពិនិត្យ ការចុះត្រួតពិនិត្យនឹងត្រូវបានលុបចោល ហើយរបាយការណ៍ស្តីពីការមិនសហការ នឹងត្រូវបានបញ្ជូនទៅអោយអាជ្ញាធរមានសមត្ថកិច្ចនៅក្នុង ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងពាណិជ្ជកម្ម ដើម្បីចាត់វិធានការសមស្រប ។

## គុណតំលៃនៃបុគ្គលិកត្រួតពិនិត្យរបស់គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*

**ក្រមសីលធម៌វិជ្ជាជីវៈ**
រាក់ទាក់ គោរពអ្នកដទៃ ផ្តោតចំលើកិច្ចការនិងបញ្ហា

**សុចរិតភាព និង ឯករាជ្យភាព**
បទដ្ឋានគុណធម៌កំរិតខ្ពស់ មានន័យថាមិនរងឥទ្ធិពលរបស់អ្នកដទៃ មិនទទួលយកអំណោយ ឬ ធ្លាក់ចូលទៅក្នុងស្ថានភាពដែលធ្វើអោយខូចខាតដល់គុណធម៌របស់ខ្លួន

**មានតម្លាភាព និង បើកចំហ**
ពន្យល់ពីដំណើការនៃការត្រួតពិនិត្យ ហើយអាចទំនាក់ទំនងជាមួយបាន និង បើកចំហចំពោះការពិភាក្សា

**អាចជឿទុកចិត្តបាន**
មិនបង្ហាញព័ត៌មានដោយគ្មានការប្រុងប្រយ័ត្ន មិនមើលរំលងបញ្ហាឬអោយតំលៃទាបលើបញ្ហា ធ្វើការតាមដានចំពោះការប្តេជ្ញាចិត្តដែលបានសន្យាហើយ

# គោលដៅនៃការត្រួតពិនិត្យ: ការរំលឹកឡើងវិញ

- ការត្រួតពិនិត្យ និង ការបណ្តុះបណ្តាល មានគោលបំណងចង្អុលបង្ហាញពីផ្នែកនានាដែលរោងចក្រមិនបានអនុវត្តទៅតាមច្បាប់ស្តីពីការងារ ជួយផ្តល់ដំណោះស្រាយដើម្បីបំពេញគំលាតទាំងនេះ និង ផ្តល់ព័ត៌មានដើម្បីកែលំអលក្ខខ័ណ្ឌការងារ ទំនាក់ទំនងការងារ និង ផលិតភាព ។
- ការត្រួតពិនិត្យ មិនមានគោលបំណងដាក់ទោសពៃរ៍លើរោងចក្រ ព្រុះញង់អោយមានកូដកម្ម ឬ ធ្វើអោយខូចខាតដល់ការប្រកបអាជីវកម្មឡើយ ។
- រោងចក្រដែលអនុវត្តសកម្មភាពកែតំរូវ អាចបង្កើនផលិតភាព ធ្វើអោយរោងចក្រក្លាយជាកន្លែងធ្វើការមួយកាន់តែប្រសើរជាងមុន និង កែលំអទំនាក់ទំនងជាមួយនឹងអ្នកបញ្ជាទិញ ដោយបង្ហាញថាអ្នកគ្រប់គ្រងយកចិត្តទុកដាក់ចំពោះក្តីកង្វល់របស់កម្មករនិយោជិត និង ការអនុវត្តន៍តាមបទដ្ឋានការងារ ។

សំរាប់ព័ត៌មានបន្ថែម សូមទាក់ទង:

អង្គការពលកម្មអន្តរជាតិ
គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*
ផ្ទះលេខ ៩ ផ្លូវលេខ ៣២២ បឹងកេងកង ១
ចំការមន ភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ: +៨៥៥ ២៣ ២១២៨៤៧ / ២២០៣៦២
ទូរសារ: +៨៥៥ ២៣ ២១២៩០៣
អ៊ីមែល: betterfactories@ilo.org
វ៉ិបសាយ: www.betterfactories.org/ilo

